# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ១៦៩ MIH / ២០១៩

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
លេខាធិការដ្ឋាន
ចូល លេខ: ២២៥២
ថ្ងៃទី: ៣០-០៨-១៩
បញ្ជូនទៅ: ...

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
ការិយាល័យ រដ្ឋបាល
ចូល លេខ: ៤៦០
ថ្ងៃទី ៣០/៨/១៩ ម៉ោង ១២:៣០
បញ្ជូនទៅ: ...

## សេចក្ដីសម្រេច
## ស្ដីពី
## ការកែសម្រួលថ្លៃលក់ទឹកស្អាត
## ដែលផលិត និងផ្គត់ផ្គង់ ដោយរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ១៥៧ អនក្រ.បក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានទឹកស្អាតនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញប្រកាសលេខ ៤៦១ MIH/2014 ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្តីពីនីតិវិធីសម្រាប់ការចេញ កែសម្រួល បន្ត ព្យួរ និងដកហូតប្រកាសអនុញ្ញាតឲ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត
- បានឃើញប្រកាសលេខ ១៤៦ MIH/២០១៧ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍រួមនៃការកំណត់ថ្លៃលក់ទឹកស្អាត
- យោងលិខិតលេខ ១៣៧ ខន/០១៩ ចុះថ្ងៃទី៣ ខែមករា ឆ្នាំ២០១៩ របស់ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- យោងលិខិតលេខ ៦៤៨៤ សហវ.អសប ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីមែល: mih.smcabinet@gmail.com

# ស ម្រេ ច

**ប្រការ១.-**

កែសម្រួលថ្លៃលក់ទឹកស្អាតដែលផលិត និងផ្គត់ផ្គង់ដោយរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ តាមការកំណត់ដូចខាងក្រោម៖

| ប្រភេទអតិថិជន | បរិមាណប្រើប្រាស់កែសម្រួលថ្មី (ម៣ ក្នុង១ខែ) | ថ្លៃលក់កែសម្រួលថ្មី (រៀល/ម៣) |
|---|---|---|
| អតិថិជនជីវភាព | មិនលើសពី ៧ម៣ ក្នុង១ខែ | ៤០០រៀល/ម៣ |
| | ពី៨ម៣ ដល់ ១៥ម៣ ក្នុង១ខែ | ៧២០រៀល/ម៣ |
| | ពី១៦ម៣ ដល់ ២៥ម៣ ក្នុង១ខែ | ៩៦០រៀល/ម៣ |
| | ពី២៦ម៣ ដល់ ៥០ម៣ ក្នុង១ខែ | ១ ២៥០រៀល/ម៣ |
| | ពី៥១ម៣ ដល់ ១០០ម៣ ក្នុង១ខែ | ១ ៩០០រៀល/ម៣ |
| | ចាប់ពី ១០១ម៣ ក្នុង១ខែ | ២ ២០០រៀល/ម៣ |
| អតិថិជនអាជីវកម្ម | មិនលើសពី ១៥ម៣ ក្នុង១ខែ | ៩៥០រៀល/ម៣ |
| | ពី១៦ម៣ ដល់ ៤៥ម៣ ក្នុង១ខែ | ១ ១០០រៀល/ម៣ |
| | ពី៤៦ម៣ ដល់ ១០០ម៣ ក្នុង១ខែ | ១ ៤០០រៀល/ម៣ |
| | ពី១០១ម៣ ដល់ ២០០ម៣ ក្នុង១ខែ | ១ ៧០០រៀល/ម៣ |
| | ពី២០១ម៣ ដល់ ៥០០ម៣ ក្នុង១ខែ | ២ ១០០រៀល/ម៣ |
| | ចាប់ពី ៥០១ម៣ ក្នុង១ខែ | ២ ៤០០រៀល/ម៣ |
| អតិថិជនជាក្រសួង-ស្ថាប័ន អង្គភាពនានា និងស្ថានទូត | មិនកំណត់តាមបរិមាណប្រើប្រាស់ | ២ ៥០០រៀល/ម៣ |

**ប្រការ២.-**

ការកំណត់ថ្លៃលក់ទឹកស្អាតដូចមានចែងក្នុងប្រការ១ខាងលើនេះ ត្រូវអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០ តទៅ។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានមជ្ឈមណ្ឌល រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និងគ្រប់អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១ រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៩

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

***កិត្តិសេដ្ឋាបណ្ឌិត* ចម ប្រសិទ្ធ**

**កន្លែងទទួល ៖**
- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិតឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋបាលរាជធានីភ្នំពេញ
- រដ្ឋបាលខេត្តកណ្តាល

*-ដើម្បីជូនជ្រាប-*
- អគ្គនាយកដ្ឋានទឹកស្អាត
- ដូចប្រការ៤

*-ដើម្បីអនុវត្តមុខការ-*
- ឯកសារ-កាលប្បវត្តិ



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៤ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខៈ (៨៥៥) ២៣ ២១១ ៧៨៥
អ៊ីម៉ែលៈ mih.smcabinet@gmail.com